# ការសំភាសន៍របស់លោកពូ ស្រេង ផល

កៈ អ្នកដែរសំភាសន៍គេមាន ជាងស៊ីអ៊ាវ ខៈ អ្នកដែរអោយគេសំភាសន៍ ស្រេង ផល

## ការសង្ខេបប្រវត្តិរបស់លោកពូ ស្រេង ផល

លោកពូ ស្រេង ផល មានអាយុ52ឆ្នាំ នៅក្នុងឆ្នាំ2018_លោកពូ ស្រេង ផល មានភេទប្រុសលោកពូ ស្រេង ផល មានទីលំនៅបច្ចុប្បន្ននៅភូមិបាល្លាំងថ្មី ឃុំរអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

កៈ ចឹងជាដំបូងខ្ញុំសូមអរគុណច្រើនពូដែរបានអោយខ្ញុំសំភាសន៍ពីប្ររវត្តិរបស់ពូ ហើយការសំភាសន៍ នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅ ជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្ររវត្តិរបស់ឪពុកម្តាយ នឹងប្ររវត្តិរបស់ដូចតា ចឹងនៅពេលដែរខ្ញុំបាន សំភាសន៍ពូហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមាន ឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសពូ ចឹងតើពូយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេពូ?

ខៈ ព្រមតើ!

កៈ ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍ពូខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ាវ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍ពូមួយនេះគឺ ធ្វើឡើងនៅថ្ងៃទី20ខែ2 ឆ្នាំ2018 សំភាសន៍នៅភូមិបាល្លាំងថ្មី ឃុំរអា ស្រុកកំពង់សៀម ខេត្តកំពង់ចាម ចឹងសំរាប់ពូឈ្មោះពេញរបស់ពូមានឈ្មោះអិគេដែរពូ?

ខៈ ខ្ញុំឈ្មោះផល ឈ្មោះស្រេង ផល

កៈ ចុះមានឈ្មោះហៅក្រៅដែរទេពូ?

ខៈ អត់មានឈ្មោះហៅក្រៅទេនឹង

កៈ ហៅក្រៅគេហៅផលចឹងហោសពូ?

ខ៖ ហៅផលនឹងហើយបើបងប្អូនវិញហៅអាពៅៗនឹង

ក៖ ចុះពូកាលពីក្មេងនឹងមាននរណាហៅឈ្មោះពូអីផ្សេងទៀតទេ?

ខ៖ គ្មានឈ្មោះហៅក្រៅអីផ្សេងទេនៅក្រៅនោះបើបងប្អូននឹងហៅតែអាពៅៗទេ

ក៖ ចឹងហៅពៅហោសពូ?

ខ៖ បើអ្នកក្រៅហៅឈ្មោះផលៗហាស

ក៖ បាទពូ ចុះពូសព្វថ្ងៃនឹងពូអាយុប៉ុន្មានដែរពូ?

ខ៖ ខ្ញុំអាយុ52ឆ្នាំ

ក៖ ចុះពូកើតនៅថ្ងៃខែឆ្នាំណាដែរពូ?

ខ៖ កើតនៅឆ្នាំ1966

ក៖ ចុះថ្ងៃខែពូមិនចងចាំទេ?

ខ៖ អត់ចាំទេដឹងតែកើតនៅ52ឆ្នាំនឹងតែម្តងនឹង

ក៖ ចុះពូឆ្នាំច័ន្ទគតិពូឆ្នាំអីគេដែរពូលក្ខណះថាឆ្នាំជូត ឆ្លូវ ខាល ថោះហាសពូ?

ខ៖ ខ្ញុំឆ្នាំមមី

ក៖ ចឹងពូឆ្នាំមមីណពូ ចុះទីកន្លែងដែរពូកើតនឹងពូកើតនៅណាដែរ?

ខ៖ កើតនៅភូមិបាល្លាំងយើងនឹង

ក៖ ចឹងកើតនៅនឹងតែម្តងហោសពូ?

ខ៖ កើតនៅបានបាល្លាំងថ្មីយើងនឹង

ក៖ ចុះពូមានបងប្អូនចមនួនប៉ុន្មាននាក់ដែរពូ?

ខ៖ មានបងប្អូនចំនួន5នាក់

ក៖ ចុះពូជាកូនទីប៉ុន្មានដែរពូ?

ខ៖ ខ្ញុំជាកូនចុងពូចគេពៅគេនឹង

កៈ  ចុះមានស្រីប៉ុន្មាន នឹងប្រុសប៉ុន្មានដែរពូ?

ខៈ  មានស្រី4នាក់ នឹងប្រុសម្នាក់

កៈ  ចុះពូអាចរៀបរាប់ពីឈ្មោះបងៗរបស់ពូបានដែរទេ ថាពួកគាត់មានឈ្មោះអីគេដែរចឹងហាសពូ?

ខៈ  បានៗតើ មួយ ស្រេង អឹម, រួចទៅ ឈ្មោះស្រេង រិណា , ឈ្មោះស្រេង រុណា , ឈ្មោះស្រេង រី,នឹងឈ្មោះ ស្រេង ផល

កៈ
ចុះពូមានចងចាំអនុស្សាវរីយ៍អីកាលពីពូនៅក្មេងៗពូធ្លាប់លេងអីគេជាមួយបងៗរបស់ពូដែរទេ?

ខៈ  គ្មានធ្លាបើលេងអីទេចុះឯងតូចនឹងស្រុកនៅជំនាន់លុនណុលហោស គេវៃគ្នាឯងនៅតូចពេកចឹងគ្មាន ទៅបានស្គាល់អីគេទេនឹង

កៈ  អូ៎!លក្ខណះថាលេងបិទពួន លេងឡឹកបាយឡអីពូ?

ខៈ  នឹងហើយលេងបិទពួន លេងឡឹកបាយឡជាមួយបងប្អូនតែប៉ុណ្ណឹងលេងតែប៉ុណ្ណឹងទេ

កៈ  បាទចឹងពូមិញនឹងធ្លាប់លេងបិទពួន នឹងលេងឡឹកបាយឡជាមួយបងប្អូនដែរ?

ខៈ  នឹងហើយលេងបិទពួន ឡេងឡឹកបាយឡជាមួយបងប្អូន4-5នាក់នឹងណាស់ នឹងហើយគ្មានលេងអី ជាមួយអ្នកក្រៅទេនឹង

កៈ  អូ៎!ចុះពូចូលចិត្តលេងអីជាមួយបងប្អូនរបស់ពូកាលពីនៅក្មេងដែរ?

ខៈ  កាលនៅក្មេងនិយាយរឿងលេងនិងមិនដឹងទេចុះកាលណុងចូលលុនណុលហើយ ចូលពលពតនឹង តែម្តងនឹងដល់ពេលដែរចូលពលពតនឹងលក់អាចម៍គោ នឹងកាប់កន្តាំងខែតនឹងហើយ

កៈ  ចុះកាលពីជំនាន់ពលពតពូគិតថាមានរឿងអីដែរលំបាកដែរពូ?

ខៈ  ជំនាន់ពលពតនឹងវាពិបាកហើយប៉ុន្តែពិបាកនឹងវានៅតូច ហើយនៅតូចនឹងគេគ្មានអោយធ្វើអីទេគេ អោយកាប់កន្តាំងខែតនឹងយកមកធ្វើជាជីហាស

កៈ ចុះពូនៅអាយុប៉ុន្មានដែរពូកាលណុង?

ខៈ ហ៉ោ!ខ្ទង់ប្រហែលជាអាយុ12ឆ្នាំអីទេនឹង

កៈ ចឹងពូនៅកងកុមារណោពូ?

ខៈ នៅកុមារកុមារតូចៗនឹងគេគ្មានទាន់អោយធ្វើអីទេគេអោយលើកអាចម៍គោទេ
ណុងហើយកាលពីនៅ ជំនាន់ណុងហាសពេលណុងវាយូរដែរណាស់

កៈ ពេលណុងគេជំលាសពូទៅណាដែរ?

ខៈ ជំលាសពីនេះទៅគេដេញទៅល្អៀកហោសស្រុកហោសនឹងហើយវាចឹង

កៈ ចុះពូដូរទៅខាងល្អៀកស្រុកនឹងពូធ្វើអីគេដែរនៅណុង?

ខៈ នៅតូចមានធ្វើអី
គ្មានធ្វើអីទេនៅតូចនឹងរួចបានគេជំលាសពីនឹងមកវិញបានគេជំលាសពីល្អៀកស្រុក
នឹងមកវិញបានមកនៅវាលខ្សាច់នឹងមកវិញហាស បានមកនៅវាលខ្សាច់នឹងវិញ

កៈ មកនៅវាលខ្សាច់នឹងប្រហែលជានៅឆ្នាំណាដែរពូ?

ខៈ មិនដឹងឆ្នាំដែរចុះកាលណុងនៅតូចៗចឹងមិនសូវដឹងរឿងឆ្នាំទេនេះវានៅស្ទើរពេក
នៅតូចណាស់មិន ទាន់ទាំងដឹងថាឪពុកស្លាប់ផងនឹង

កៈ បាទពូ?

ខៈ មិនដឹងថាពុកស្លាប់ជំនាន់អាពតមិនដឹងថាឪពុកយកទៅកប់នៅណា
មិនដឹងថាឪពុកស្លាប់ថ្ងៃណា មិនដឹងថាស្លាប់ដោយជំងឺអីទៀតនឹង

កៈ បាទពូបាទ?

ខៈ វាអត់ដឹងអីសោះនឹងវានៅស្ទើរនឹងគេអោយយើងនៅតែក្នុងកុមារនឹង
យើងដឹងថាឪពុកយើងស្លាប់នឹង គេមិនអោយយើងទៅផងនឹង

កៈ បាទពូបាទចឹង?

ខៈ គាត់ស្លាប់នៅជំនាន់ពលពតនឹងឪពុកនឹងហាស

កៈ ចុះពូពេលណុងគេអោយធ្វើអីគេដែរលើកអាចម៍គោ?

ខៈ លើកអាចម៍គោ

កៈ ចឹងលើកតែអាចម៍គោទេណពូ?

ខៈ គ្មានធ្វើអីទេលើកតែអាចម៍គោនឹងដាក់ក្នុងរណ្ដៅគេចឹងទៅណាស់

កៈ ប៉ុន្តែដូចជាពូទៅនៅតែឯងរឺមួយពូទៅនៅជាមួយក្រុមគ្រួសារ?

ខៈ អត់ទេទៅនៅកងចល័តណែកុមារតូចៗនឹងគេអោយទៅនៅកុមារម្ដុំៗនឹងហាស

កៈ ប៉ុន្តែគ្រួសាររបស់ពូនឹងនៅកន្លែងផ្សេង?

ខៈ គេនៅផ្សេងនឹងហើយ

កៈ ចុះបងៗរបស់ពូគាត់ទៅណាដែរ?

ខៈ បងៗនឹងគេបែកអស់ហើយនឹង

កៈ គេទៅណាទៅពូ?

ខៈ ទៅកងចល័តអស់ទៅនឹង

កៈ ប៉ុន្តែគេធំៗអស់ហើយណពូ?

ខៈ
គេធំៗហើយនឹងចុះឯងនៅពៅគេមិនតូចជាងគេនឹងដោយសារតែយើងពៅចឹងសូម្បីតែឪពុកនឹង មិនដឹងថាគាត់ស្លាប់ម៉េចអីម៉េចផងនឹង

កៈ ប៉ុន្តែគេមានជំលាសពូទៅណាអីផ្សេងទៀតអត់ពូ?

ខៈ
អត់មានទេកាលពីជំនាន់ទាហ៊ានលុនណុលគេបាញ់គ្នានឹងឯងនៅវាលខ្សាច់នឹងគេបាញ់ហើយគេ បានជំលាសយើងទៅល្មៀកតែម្ដងនឹង

កៈ ប៉ុន្តែនិយាយចឹងយើងនៅនឹងរហូតែម្ដង?

ខៈ អត់នៅរហូតទេយើងនៅណុងប្រហែលជា4-5ខែនឹងបានគេអោយយើងមកវិញនឹង

កៈ ប៉ុន្តែដល់ពេលដែរយើងមកវិញចឹងទៅយើងធ្វើអីគេដែរ?

ខៈ ដល់ជំនាន់ពលពតនឹងតែម្ដងនឹង

កៈ ប៉ុន្តែគេអោយយើងធ្វើអីគេនៅនឹង

ខៈ នៅនឹងអត់មានធ្វើអីទេលើកតែអាចម៍គោណុងហាស
ប៉ុន្តែម៉ែឪពុកនឹងហាសគាត់ដកស្ទូង គាត់ធ្វើស្រែធ្វើចំការនឹងហាស

កៈ អូ៎!ពេលដែរយើងមកនៅនឹងវិញយើងមកនៅជាមួយម៉ែឪពុកវិញហើយ?

ខៈ អត់នៅជាមួយម៉ែឪទេនឹងម៉ែឪដោយផ្សេង
ហើយនឹងយើងកុមារដោយផ្សេងកាលនៅតូចៗនឹងហាស

កៈ ប៉ុន្តែម្ដាយឪពុករបស់ពូគេអោយទៅណាទៅពេលណុង?

ខៈ គាត់បានមកនៅល្អាងវិញ នៅល្អាងនឹងគាត់នៅមានផ្ទះមានសំបែងហាស
ប៉ុន្តែគ្រាន់តែយើងនឹងគេ បញ្ជូនអោយនៅកងចល័តតូចៗនឹងហាស

កៈ នៅកងកុមារ?

ខៈ នៅកងកុមារតូចៗនឹងទេមានអាយុ10ឆ្នាំនឹង12ឆ្នាំ
នឹងអាយុ9ឆ្នាំអីនឹងទេអោយយើងលើកអាចម៍គោ លើកអាចម៍ក្របីនឹងហាស

កៈ បាទពូបាទចឹង?

ខៈ នឹងហើយដាកជីនឹង

កៈ រហូតទាល់តែដាច់ពលពតមានការរំដោះនឹងពូមានការលំបាកអីផ្សេងទៀតទេពូ?

ខៈ អូ៎!រឿងពិបាកនឹងពិបាកលែងនិយាយហើយនឹងក្មួយពិបាកមែនទែននឹងហាស
ចុះយើងរកស៊ីអត់ឪពុកហោស

កៈ បាទពូ?

ខៈ យើងអត់ឪពុកប៉ុន្តែមានម្ដាយហើយពិបាកនឹងពិបាកតែយើងរកស៊ីឡើងត្នោតអីចឹងទៅ
យើងវែកទឹកត្នោតយកទៅលក់ទៅណាស់
ចុះកាលណុងនៅដូរអង្ករណាមានទាន់បានចាយលុយណា

កៈ ពេលណុងមានទាន់មានលុយចាយទេណពូ?

ខៈ មិនទាន់មានលុយចាយទេនឹងដូរអង្ករជាពិសេសនឹងលក់អូសនឹងតែម្តង

កៈ អូ៎!ពូរកអូសទៅលក់ហោស?

ខៈ រកអូសលក់នឹងរែកអូសលក់ដូរអង្ករ

កៈ រហូតទាល់តែដល់ឆ្នាំណាបានគេចាប់ផ្តើមចាយលុយដែរពូ?

ខៈ
មិនដឹងថាឆ្នាំណាទេគេចាប់ផ្តើមចាយលុយដល់ពេលបានចេញមួយកាក់ៗនឹងបានគេចាប់ផ្តើមចាយ លុយហើយនឹងគេចាយអង្ករ
គេចាយមាសនឹងហើយកាលណុងនៅ10គីឡូនឹងមួយជីនៅឡើយទេហី

កៈ មាន10គីឡូស្មើរមួយជី?

ខៈ បាន10គីឡូនឹងស្មើមួយជីដល់ពេលដែរយើងលក់អូសទៅទិញអង្ករចឹងទៅនឹងយកមាសទៅដូរមាស
មួយជីនឹងបានអង្ករ10គីឡូរឺ12គីឡូអីចឹងយើងដឹងតែចឹងទេគ្មានដឹងអីទេពេលណុងនៅតូចនឹងហើយគ្មាន ដឹងអីទេនៅរែកអូសលក់នឹងតែម្តងនឹងដូរអង្ករនឹងតែម្តង

កៈ ចុះពេលណាដែរពូគិតថាពូបានមកនៅជួបជុំក្រុមគ្រួសារពូវិញហាស
ដូចជាពេលណាដែរ?

ខៈ ដាច់ពលពតនឹងមកនៅជុំគ្នាវិញហើយនឹង

កៈ អូ៎!ចឹងពេលណុងមកនៅជុំគ្នាវិញនឹង?

ខៈ មកនៅបងប្អូនមកនៅជុំគ្នាវិញហើយនឹងយើងរែកអូសដូរអង្ករនឹងហាស

កៈ បាទពូបាទ?

ខៈ នឹងហើយរែកអូសដូរអង្ករ ចំណែកបងៗនឹងគេធ្វើការទៅ
នឹងទៅណាទៅណីទៅទៅយកអូសទៅអា បងអ្នកកាប់យើងអ្នករែកទៅ

កៈ រហូតដល់ឆ្នាំកៅជាងនឹងបានប្រទេសយើងនឹងស្ថេរភាពណពូ?

ខ៖  នឹងហើយបានស្ពេរភាពនឹងហើយនៅជំនាន់ណុងដឹងតែរត់ហើយឯងនៅរៀនហោស

ក៖
ប៉ុន្តែសុំសួរមួយពូពេលដែរឆ្នាំប៉ៃតជាងដាច់ពលពតភ្លាមៗនឹងមានគេចាប់យើងយកទៅធ្វើជាទាហ៊ាន មែនទេពូ?

ខ៖  ចាប់យកទៅធ្វើជាទាហ៊ាន

ក៖  ប៉ុន្តែពេលណុងគេចាប់ពូអត់ ពូនៅតូចៗពេករឺយ៉ាងម៉េចដែរពូ?

ខ៖  ខ្ញុំនៅតូចពេកនៅរៀននឹង នៅរៀនគេមិនយកទេនៅតូចពេកហោស

ក៖  ប៉ុន្តែគេយកនឹងចាប់ពីអាយុប៉ុន្មានដែរពូ?

ខ៖  ហ៎ៅអាយុទេគេយកចាប់ពីអាយុ17-18ឆ្នាំរហូតអាយុ30ឆ្នាំជាងអីនឹងអោយតែធំនឹងគេយកទាំងអស់ នឹងហាសអោយទៅក5ទៅកអីទៅណាស់នឹងហើយ

ក៖  បាទពូ ចុះសំរាប់សព្វថ្ងៃនឹងបងៗរបស់ពូនឹងពួកគាត់នៅណាដែរពូ?

ខ៖  មានមួយនៅល្អាង មានមួយនៅបាល្លាំង មួយទៀតនៅតាខុងហោស
មួយនឹងនៅពព្រក

ក៖  ប៉ុន្តែនៅក្នុងខេត្តកំពង់ចាមយើងនឹងទេ?

ខ៖ នៅក្នុងខេត្តកំពង់ចាមប៉ុន្តែវានៅបែកឆ្ងាយៗពីគ្នា

ក៖  ប៉ុន្តែពួកគាត់ធ្វើអីគេខ្លះដែរពូ?

ខ៖  គាត់ធ្វើស្រែចំការដែរនឹង

ក៖  ទាំងអស់គ្នាតែម្តង?

ខ៖  ទាំងអស់នឹងតែម្តងគ្មានធ្វើអីទេ គ្មានវិនិយោគទន់អីទេធ្វើស្រែចំការនឹង

ក៖  បាទពូចុះឪពុករបស់ពូនឹងឈ្មោះអីគេដែរពូ?

ខ៖  ឈ្មោះគូ ស្រេង

ក៖ ចុះគាត់ដល់សព្វថ្ងៃនឹងគាត់អាយុប៉ុន្មានដែរពូដឹងទេដល់ឥឡូវនឹងហាស?

ខ៖ ហ៉ោ!មិនដឹងទេគាត់ស្លាប់នៅជំនាន់ពលពតនឹងម៉េចដឹងបើឯងមិនដឹងថាគាត់ស្លាប់ពេលណាផង នឹងហើយគាត់ស្លាប់នៅជំនាន់ពលពត

ក៖ ចុះពូមានដឹងថាគាត់កើតនៅណាទេ?

ខ៖ គាត់កើតនៅភូមិពង្រ

ក៖ នៅភូមិពង្រនឹងនៅណាវិញពូ?

ខ៖ ភូមិពង្រនឹងនៅជើងហោសភូមិពង្រនឹងនៅជិតវត្តថ្មីនឹង

ក៖ អូ៎!ជិតដល់ទ្រានណាពូ?

ខ៖ នឹងហើយនៅជិតទ្រាននឹងនៅជិតវត្តថ្មីនឹង

ក៖ ចុះម្ដាយរបស់ពូនឹងគាត់មានឈ្មោះអីគេដែរពូ?

ខ៖ ម្ដាយរបស់ខ្ញុំនឹងឈ្មោះសៅ គីម

ក៖ ចុះគាត់អាយុប៉ុន្មានដែរពូមានចងចាំអត់?

ខ៖ គាត់អាយុ82ឆ្នាំហើយ

ក៖ ចុះគាត់កើតនៅឆ្នាំណាពូមានចងចាំទេពូ?

ខ៖ អត់ដឹងទេគាត់អាយុ82ឆ្នាំហើយ

ក៖ ចុះគាត់កើតនៅណាដែរពូមានដឹងទេពូ?

ខ៖ គាត់កើតនៅភូមិវាលខ្សាច់នឹង

ក៖ បាទពូចឹងម្ដាយរបស់ពូនឹងគាត់កើតនៅឆ្នាំ1936?

ខ៖ នឹងហើយនៅឆ្នាំ1936

ក៖ បាទពូចុះឪពុករបស់ពូនឹងកាលពីគាត់នៅរស់នឹងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរពូ?

ខ៖  គាត់ធ្វើស្រែធ្វើចំការនឹងហើយ

ក៖  ចុះគាត់ជាមនុស្សបែបណាដែរស្លូតរឺមួយក៏កាច?

ខ៖  អ៎ូ!ឪពុករបស់ខ្ញុំនឹងស្លូតណាស់ឪពុកខ្ញុំនឹងស្លូតណាស់

ក៖  ចុះម្ដាយរបស់ពូនឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរពូ?

ខ៖  គាត់ធ្វើស្រែចំការដែរនឹងគាត់ទៅលក់ដូរប៉ុន្តែគាត់ជាអ្នកលក់ដូរចឹងហាស

ក៖  ប៉ុន្តែម្ដាយរបស់ពូនឹងសព្វថ្ងៃគាត់នៅរស់ទេណាពូ?

ខ៖  គាត់ស្លាប់ហើយនឹង

ក៖  អ៎ូ!ចឹងគាត់ស្លាប់ហើយណាពូ?

ខ៖  គាត់ស្លាប់ហើយអាយុ82ឆ្នាំហើយនឹងគាត់ស្លាប់ហើយ

ក៖  អ៎ូ!ចុះគាត់ជាមនុស្សយ៉ាងម៉េចដែរពូស្លូតរឺមួយក៏កាច?

ខ៖  ម្ដាយស្លូតណាស់ចិញ្ចឹមកូនទាំងក្រោលមាន5នាក់មិនមែនតិចទេណាស់
អត់ពីប្ដីគាត់ទៅគាត់ចិញ្ចឹម កូន5នាក់ហាស

ក៖  បាទពូបាទ?

ខ៖  ពិបាកវេទនាណាស់គាត់ចិញ្ចឹមកូនហោសគាត់មេម៉ាយមិនចឹង

ក៖  បាទពូត្រូវ?

ខ៖  មិនមែនស្រួលទេគាត់មេម៉ាយចឹងកូនហោសនឹងហើយ

ក៖  ចុះពូមានចងចាំអនុស្សាវរីយ៍អីកាលពីពូនៅជាមួយឪពុកម្ដាយរបស់ពូទេ?

ខ៖  អនុស្សាវរីយ៍អត់មានអីទេ
វានៅតូចពេកមិនដឹងថាបានជាលេងស្អីទេភ្លេចអស់ហើយនឹង អនុស្សាវរីយ៍នឹងហាស

ក៖  អត់ទេចង់និយាយកាលពីពូនៅជាមួយម្ដាយឪពុករបស់ពូចឹង
មានអនុស្សាវរីយ៍អីថាពូធ្លាប់ទៅស្រែជា មួយឪពុកម្ដាយរបស់ពូទេ?

ខ៖ ឪពុកអត់មានបានទៅស្រែទេ
បើម្ដាយនឹងមានឪពុកស្លាប់ជំនាន់ពលពតហាសរួចពីពលពតទៅម្ដាយ
នឹងគ្រប់គ្រងកូន5នាក់នឹងហាស

ក៖ បាទពូបាទ?

ខ៖ ហើយខ្ញុំបានតៅស្រែជាមួយម្ដាយបានទៅស្ទូងស្រូវស្រែជាមួយម្ដាយអីចឹង
នឹងម្ដាយរបស់ខ្ញុំគាត់ជា អ្នកគ្រប់គ្រងចឹងហាស

ក៖ បាទពូបាទ?

ខ៖ នឹងហើយ

ក៖ ប៉ុន្តែម្ដាយរបស់ពូនឹងស្រលាញ់ពូជាងគេហីពូ?

ខ៖ ស្រលាញ់នឹងហើយចុះបើកូនពៅហើយនឹង

ក៖ ចុះម្ដាយគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅពូទេ?

ខ៖ គាត់ដូចជាមិនដែរប្រាប់ពីប្រវត្តិអីទេប៉ុន្តែគ្រាន់តែគាត់ប្រាប់ចេះ
គាត់ថាអញ់នៅពីក្មេងនឹងអញ់ធ្វើការ ងារនឹងអញ់ស្រលាញ់ម៉ែឪអញ់ណាស់ចឹងហាស
គាត់ប្រាប់ប្រវត្តិគាត់ចឹងហាស

ក៖ បាទពូបាទ?

ខ៖ គាត់ស្រលាញ់ម៉ែណាស់ដល់ពេលដែរខ្ញុំមក
ដល់ពេលដែរខ្ញុំដឹងក្ដីខ្ញុំមកខ្ញុំស្រលាញ់ម៉ែខ្ញុំដែរនឹង
គាត់មិនដែរបានធ្វើបាបខ្ញុំទេខ្ញុំជាកូនពៅហោស

ក៖ បាទពូចឹង?

ខ៖ មិនដែរឃើញម្ដាយវៃពួកកូនយ៉ាងម៉េចទេមិនឃើញទេទាំងអស់នឹង

ក៖ ប៉ុន្តែឪពុកពូមិនទាន់ទេ?

ខ៖ ឪពុកនឹងមិនទាន់ទេគាត់ស្លាប់ជំនាន់ពលពតនឹងយើងមិនដឹងផងនឹង

ក៖ បាទពូបាទ?

ខ៖  យើងអត់ដឹងផង

ក៖  បាទពូចុះយាយតាខាងម្ដាយនឹងពូមានស្គាល់ឈ្មោះគាត់ដែរទេពូ?

ខ៖  យាយតាខាងម្ដាយស្គាល់តើ!

ក៖  យាយតាខាងម្ដាយនឹងគាត់ឈ្មោះអីគេដែរពូ?

ខ៖  ឈ្មោះគូ ស្រេង

ក៖  ចុះយាយវិញពូ?

ខ៖  យាយឈ្មោះអីគេថៃតា ភី នឹងយាយ គូ ឪពុកតាស្រេងនឹង

ក៖  នឹងខាងម្ដាយណាពូ?

ខ៖  ខាងឪពុកនឹង

ក៖  ចុះខាងម្ដាយវិញ?

ខ៖  បើខាងម្ដាយវិញ យាយកៀន តាសៅនឹង

ក៖  ប៉ុន្តែពូមានចងចាំថាពួកគាត់កើតនៅណាទេពូ?

ខ៖  គាត់កើត?

ក៖  ចង់និយាយថាទាំងខាងឪពុក នឹងខាងម្ដាយនឹងគាត់កើតនៅណាខ្លះដែរពូ?

ខ៖  គាត់កើតនៅក្នុងភូមិនឹង

ក៖  ទាំងអស់គ្នាហោសពូ?

ខ៖  ទាំងអស់គ្នាកើតនៅក្នុងភូមិនឹង

ក៖  ចុះពូមករស់នៅក្នុងភូមិនឹងយូរនៅពូ គ្រួសាររបស់ពូហាស?

ខ៖ ប្រហែលជា30ឆ្នាំជាងហើយនឹងតាំងពីជាចពលពតមកម្ល៉េសនឹង

ក៖  ចឹងមានន័យថាមុនពលពតនឹងពូនៅណាដែរ?

ខ៖  មុនពលពតនៅល្អាង នៅពលពតនឹងនៅល្អាងនឹងតែម្ដងនឹងនៅល្អាងលើនឹង

កៈ  អ៊ូ!ដល់ពេលដែរដាច់ពលពតគេរំដោះហើយពូមកនៅនឹងតែម្តង?

ខៈ  មកនៅនឹង ដល់ពេលដែរដាច់នឹងមកនៅនឹងតែម្តងនឹង

កៈ  ចឹងមានន័យថាពេលដែរដាច់ពលពតនឹងវាចូល40ឆ្នាំហើយនឹងវា39ឆ្នាំ?

ខៈ  នឹងហើយអស់39ឆ្នាំនឹងហើយ

កៈ  ចុះពូមានបងប្អូនរឺមួយក៏កូនចៅនរណាគេម្នាក់ដែររស់នៅក្រៅប្រទេសទេពូ?

ខៈ  អ៊ូ!អត់មានសោះ

កៈ  អត់មានទេហោស?

ខៈ អត់មានបងប្អូនកូនចៅណាទៅរស់នៅក្រៅប្រទេសនៅស្រុកចិន ស្រុកថៃ នៅអាមេរិចអីអត់មានសោះ តែម្តងនឹង

កៈ  នៅខ្មែរទាំងអស់គ្នានឹង?

ខៈ នៅតែស្រុកខ្មែរនឹងចឹងបានយើងក្រនឹងហាស គ្មាននរណាទៅប្រទេសគេនឹង

កៈ  ចុះភរិយារបស់ពូនឹងមានឈ្មោះអីគេដែរពូ?

ខៈ  មានឈ្មោះហាក់ គឹមសុខ

កៈ

អ៊ូ!បាទចុះពូមានចងចាំអនុស្សាវរីយ៍អីទេថ្ងៃខែដែរពូបានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាអីចឹង ចូលសាច់រឿងហោសពូ?

ខៈ  វាមិនបានចាំទេគ្រាន់តែស្រលាញ់ម៉ែឪចូលដណ្តឹងរៀបការអីចឹងទៅណាស់ អោយចាំអនុស្សាវរីយ៍អី អត់មានទេ

កៈ  ប៉ុន្តែពូមានចងចាំថានៅថ្ងៃខែឆ្នាំណាហាស?

ខៈ  ថាវាមិនដឹងវាភ្លេចទៅណាស់

កៈ  ចុះកូនបងរបស់ពូនឹងគាត់អាយុប៉ុន្មានដែរពូ?

ខៈ អាយុ25ឆ្នាំហើយ

កៈ អាយុ25ឆ្នាំចឹងនៅពេលដែរពូការភ្លាមពូមានកូនភ្លាមរឺយ៉ាងម៉េចដែរ?

ខៈ អត់ទេបាន3ឆ្នាំដែរបុត្រ

កៈ ចឹងមានន័យថាពូការអស់រយះពេល28ឆ្នាំហើយនឹង?

ខៈ នឹងហើយអស់28ឆ្នាំហើយ

កៈ ចឹងនៅពេលដែរពូចូលស្ដីដណ្ដឹងមីងនឹង ពូគិតថាដូចជាពូជាអ្នករៀបចំដោយខ្លួនឯងរឺឪពុកម្ដាយជាអ្នកអោយដែរ?

ខៈ ឪពុកម្ដាយអ្នកចូល ដូចថាយើងស្រលាញ់អ្នកឈ្មោះកចឹងហាស

កៈ បាទពូ?

ខៈ ដល់ពេលដែរស្រលាញ់ឈ្មោះក ចឹងយើងអោយម៉ែឪទៅដណ្ដឹង រួចម៉ែឪរបស់យើងនឹងទៅដណ្ដឹង នឹងទៅជាមួយក នឹង

កៈ បាទពូ?

ខៈ

មិនអាចស្រលាញ់ខ្លួនឯងបានទេបើយើងស្រលាញ់នឹងត្រូវចូលដណ្ដឹងទៅខាងស្រីនឹងហោស

កៈ បាទមានជាថ្លៃទឹកដោះទេពូ ថ្លៃជំនូនហាស?

ខៈ បង្គាប់ដែរតើបង្គាប់ថ្លៃទឹកដោះដែរតើ គេមិនយកលុយទេគេយកជាគុខាងប្រុសវិញ

កៈ ចឹងហោសពូ ចឹងមានន័យថាយើងចេញគុអោយគេទៅ?

ខៈ ដូចថាយើងធ្វើបាយម្ហូបចឹងនឹងចេញគុអោយគេដូចថា20គុអីចឹងគេមិនយកពីយើងទេ

កៈ ខាងគេមិនចេញទេចេញតែខាងយើង?

ខៈ ចេញតែខាងប្រុសនឹងចុះខាងប្រុសទៅដណ្ដឹងខាងស្រីនឹង

កៈ អូ៎!បាទពូ?

ខៈ នឹងហើយគេធ្វើអោយយើងស៊ី

កៈ ឪឡូវនឹងចូលពីប្រវត្តិស្នេហាម្តង ចុះពូជួបមីងនៅពេលណា ហើយពូស្រលាញ់មីងរយះពេលប៉ុន្មាន ដែរពូចូលស្តីដណ្តឹងមីង ហើយហេតុអីបានជាពូចាប់អារម្មណ៍មីង?

ខៈ កាលណុងឯងទៅចេះចេញពីរៀនមកទៅការគេ ចេញពីរៀននឹងទៅការគេហើយគេអោយទៅ កត់ចំណាងដៃចឹងហាស

កៈ បាទពូបាទ?

ខៈ ដល់ហើយឃើញប្រពន្ធនឹងមកស៊ីការហ៎ាយឃើងមិននៅកត់ចំណាងដៃដល់ហើយឃើងថា ស្រលាញ់ ប្រពន្ធនឹងចឹងស្រលាញ់ស្រីនឹងចឹងហាស រួចអោយម៉ែឪនឹងចូលស្តីដណ្តឹងទៅកាលណុងនៅរៀន

កៈ ចុះពូស្រលាញ់គាត់ប្រហែលជារយះពេលប៉ុន្មានបានពូចូលស្តីដណ្តឹងគាត់?

ខៈ ប្រហែលជាមួយខែនឹងណាស់

កៈ លឿនម៉េសពូ?

ខៈ លឿនពេកនឹងមួយខែនឹង តែមួយខែនឹងចូលដណ្តឹងនឹង

កៈ ដូចជាឆាប់ពេកទេហីពូ?

ខៈ ហ៎ា!ខំមកពីចាស់ៗៗទេ ចាស់ៗថាហែងចាស់ហើយហែងយកប្រពន្ធទៅ ខំអីមិនយកប្រពន្ធទេ

កៈ ខឹងគេថាចាស់ពេកហោសពូ?

ខៈ គេថាចាស់ហើយហែងយកប្រពន្ធទៅពេលណុងរៀនបានច្រើនដែរនឹងរៀនបានថ្នាក់ទី9ដែរតើ!

កៈ អូ៎!ពូរៀនបានថ្នាក់ទី9ហោសពូ?

ខៈ រៀនបានថ្នាក់ទី9នឹងហើយ រៀនបានថ្នាក់ទី9ហាស

កៈ ចុះកាលពីពូរៀននឹងពូរៀននៅណាដែរ?

ខៈ រៀននៅជូនណាត

កៈ រៀននៅសាលាជូនណាត?

ខៈ
ពេលដែររៀននៅជូនណាតទៅបានបកមករៀននៅសាលាលីសេបានទៅការតែម្តងនឹង

កៈ ប៉ុន្តែពីមុននឹងពូរៀននៅជូនណាតនឹងពូរៀនបឋមសិក្សានៅណាដែរទៅ?

ខៈ បឋមសិក្សានឹងរៀននៅថ្មគោល

កៈ អូ៎!រៀននៅថ្មគោលយើងនឹងហោស?

ខៈ នឹងហើយរៀននៅថ្មគោលហើយដល់ថ្នាក់ទី5ទៅបានទៅរៀននៅជូនណាតនឹង

កៈ រៀននៅជូនណាតនឹង?

ខៈ ចូលថ្នាក់ទី5 ទី6 ទី7 ទី8 ទី9បានប្រលងឌីប្លូមបានចូលសាលាលីសេ
ដល់ថ្នាក់តី9នឹងបានយើងការទៅណាស់ នឹងចាំប្រវត្តិច្បាស់ណាស់
យើងរៀននឹងមិនតិចឆ្នាំទេណាស់

កៈ ប៉ុន្តែពេលណុងពូនៅអាយុប៉ុន្មានដែរពូ?

ខៈ ហាស?

កៈ ពូនៅអាយុប៉ុន្មានដែរ?

ខៈ ឯងនៅអាយុ22ឆ្នាំ

កៈ អូ៎!ពូការអាយុ22ឆ្នាំហោស?

ខៈ ការអាយុ22ឆ្នាំនឹង ហើយប្រពន្ធនឹងអាយុ16ឆ្នាំ

កៈ ពូអាយុ22ឆ្នាំចឹងមានន័យថាពូការអស់រយៈពេល30ឆ្នាំហើយចឹង?

ខៈ ការអស់30ឆ្នាំហើយនឹង
ឥឡូវនឹងអាយុ52ឆ្នាំលើស30ឆ្នាំហើយចុះបានកូនអាយុ26ឆ្នាំហើយនឹង

កៈ បាទពូចុះពូមានចេះភាសាអីក្រៅពីភាសាខ្មែរទេពូ?

ខៈ អត់ចេះសោះភាសាចេះតែភាសាខ្មែរតែម្តងនឹង ភាសាចិន ភាសាថៃ ភាសាវៀតណាមអីមិនចេះទេ

កៈ ចុះពូធ្លាប់មានមិត្តភក្តិណាជិតស្និទ្ធិណាដែរធំធាត់មកជាមួយគ្នាដែរទេពូ?

ខៈ មានប៉ុន្តែគេឥឡូវនឹងគេបែកអស់ទៅ

កៈ ចុះពូអាចប្រាប់ឈ្មោះមួយចំនួនដែរពូចាំបានទេ?

ខៈ បានតើ!ឯងស្គាល់ច្បាស់ជាងគេមានតែអាហ៉តមួយទេនៅឯចំនៀងទ្រានហោស តែឥឡូវនឹងគេមាន នៅដល់ភ្នំពេញហើយចឹងគេក៏ភ្លេចយើងទៅណាស់

កៈ បាទពូ?

ខៈ ចុះគេមានហើយចឹងម៉េចរាប់អានយើងយើងក៏មិនទៅរាប់អានគេដែរ

កៈ បាទត្រូវហើយពូ?

ខៈ ក៏មិនរាប់អានគេដែរ

កៈ ចុះពូអាចប្រាប់ពីដូចថាមានអនុស្សាវរីយ៍អីជាមួយមិត្តភក្តិជិតស្និទ្ធិរបស់ពូដែរទេ កាលពីនៅក្មេងៗ ហាសធ្លាប់ធ្វើអីជាមួយគ្នាហាស?

ខៈ មានដូចថាយើងទៅរៀនឹងយើងក្រីក្រជាងគេណាស់អ៊ាវ យើងក្រីក្រជាងគេប៉ុន្តែអាពូកម៉ាក់នឹងម៉ែឪ គេស្រលាញ់យើងណាស់ ហើយគេទិញសៀវភៅយើងក្រហើយយើងកំព្រាមានតែម្តាយអត់មានឪពុកចឹង ហាសអត់មានប្តីចឹងហាស

កៈ បាទពូបាទ?

ខៈ យើងទៅរៀនពិសេសនឹងយើងទៅវត្តតែម្តងនឹងចេញពីម៉ោង10-11នឹងយើងទៅវត្តទៅទៅស៊ីបាយ វត្តទៅណាស់

កៈ បាទពូបាទ?

ខ៖
នឹងនៅវត្តថ្មគោលយើងនេះគេអោយយើងស៊ីបាយរួចនឹងយើងក៏ចេញមកផ្ទះមកមានតែប៉ុណ្ណឹងទេ ប្រវត្តិកំសត់នឹងហោសស៊ីបាយវត្តទេនឹងហើយ

ក៖ ចុះពូ?

ខ៖ មិនមែនស៊ីរាល់ថ្ងៃទេណាស់

ក៖ ចុះពូធ្លាប់តៅធ្វើស្រែចំការដែរណាពូ?

ខ៖ ធ្លាប់តាអើរធ្វើស្រែចំការនឹង ធ្វើស្រែភ្ជួរស្រែ

ក៖ ចុះពូធ្លាប់បើកអាជីវកម្មលក់ដូរអីទេពូ?

ខ៖ អត់មានអាជីវកម្មអីទេធ្វើតែស្រែនឹងឡើងត្នោតតែម្តងនឹង ឡើងតែត្នោតនឹង

ក៖ ចុះពូរាល់ថ្ងៃនឹងពូមានចិញ្ចឹមសត្វអីទេពូ?

ខ៖ មានសត្វ សត្វអីនឹងមានគោនឹង

ក៖ ចិញ្ចឹមជាលក្ខណះជាកសិដ្ឋានរឺយ៉ាងម៉េចដែរពូ?

ខ៖ អត់ទេមិនមែនកសិដ្ឋានទេចិញ្ចឹមលក្ខណះជាគ្រួសារ

ក៖ ចឹងជាគ្រួសារណាពូ?

ខ៖ នឹងហើយជាគ្រួសារ

ក៖ ចុះពូគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះនឹងពូធ្លាប់បានធ្វើការងារអីគេខ្លះដែរពូ?

ខ៖ ធ្វើការនឹងគ្មានធ្វើការអីទេចេញពីរៀនមកនឹង យកប្រពន្ធយកប្រពន្ធមកឡើងត្នោតពេលដែរឡើង ត្នោតមកប្រពន្ធរកលក់ត្រីអីនៅក្នុងផ្សារនឹងទៅ
ប្តីឡើងត្នោតនឹងហើយតែប៉ុណ្ណឹងប្រវត្តិនឹង

ក៖
ចុះពូគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះហាសពូគិតថាជីវិតរបស់ពូនឹងមានការផ្លាស់ប្តូរអីគេខ្លះ ដែរពូ?

ខ៖ ផ្លាស់ប្តូរគ្មានការផ្លាស់ប្តូរអីទេគ្រាន់តែ
ផ្លាស់ប្តូរពីយើងដាច់ពលពតមកនឹងយើងពិបាកវេទនាហើយ ណាស់

ក៖ បាទពូ?

ខ៖
គ្រាន់តែថាឥឡូវនេះវាបានធូរមួយកំរិតដែរវាបានកូនធំៗរកស៊ីចិញ្ចឹមឪពុកម្តាយដែរវាចឹង
ហាស

ក៖ បាទពូបាទ?

ខ៖ នឹងហើយវាធូរចឹងប៉ុន្តែគ្មានឡាន គ្មានម៉ូតូល្អអីជិះនឹងគេទេ
មានតែកង់មានតែម៉ូតូកញ្ចាស់នឹងជិះទៅ
តែអោយមានឡានរកលុយទិញបាននឹងមិនបានទេ ចុះយើងរកតិចតួចនឹង

ក៖ ចុះពូចូលចិត្តពិសារម្ហូបអីគេដែរពូ?

ខ៖ រឿងម្ហូបនឹងសំលម្ជូរ
សំលប្រហើរនឹងសំលយើងធម្មជាតិនឹងធម្មតាទាំងអស់នឹងហើយមានតែ
ស៊ីប្រហុកអីនឹងទៅ

ក៖ ចុះតាំងពីក្មេងហាល្បែងប្រជាប្រិយ៍អីដែរពូចូលចិត្តលេងដែរលក្ខណះថាចោលឈូង
ទាញព្រាត បោះអង្គុញ លាក់កន្សែង?

ខ៖ លេងលេងចោលឈូង បោះអង្គុញនឹងកាលនៅស្វាវៗនឹងហាស

ក៖ បាទពូបាទ?

ខ៖ ចូលឆ្នាំចូលអីនឹងលេងអង្គុញលេងអីនឹង គ្មានដែរលេងបៀរ
លេងអាប៉ោងអីនឹងមិនដែរស្គាល់ទេ ខ្ញុំមិនដែរលេងទេបៀរអាប៉ោងហោស

ក៖ ចុះពូមានចេះច្រៀងទេពូ?

ខ៖ អត់ចេះសោះ

ក៖ ពូអាចដាក់មួយបទសិនទៅ?

ខ៖ អត់ទេមិនចេះទេមិនចេះច្រៀងយ៉ាងម៉េចទេ

ក៖ ចុះពូចូលចិត្តស្ដាប់បទចំរៀងទេពូ?

ខ៖ បើចំរៀងខ្ញុំចូលចិត្តស្ដាប់ណាស់

ក៖ លក្ខណះបទបែបបុរាណរឺមួយបទសម័យដែរពូ?

ខ៖ អូ៎!បុរាណតែម្ដងនឹង សម័យស្អប់ប្រភេទលេខហើយសម័យស្អប់ណាស់

ក៖ បាទពូបាទ?

ខ៖ បើគេជ្រុះកាសែត2ឡានងីក៏មិនរើសដែរនឹង បើស៊ិនស៊ីសាម៉ុត រស់សារីសុធា ប៉ែនរនអីនឹងមក

ក៖ បាទពូចូលចិត្ត?

ខ៖ ចូលចិត្តស្ដាប់ណាស់ចំរៀងឥឡូវនឹងមិនចូលចិត្តទេអ៊ារ មិនចូលចិត្តសោះហើយនឹង

ក៖ ចុះពូចូលចិត្តស្ដាប់រឺមួយចូលចិត្តមើលយីកេអាយៃអីទេពូ
រឺមួយក៏ពូចូលចិត្តមើលល្ខោនអីទេ?

ខ៖
ល្ខោននឹងចូលចិត្តមើលដែរអើរអានឹងប្រពៃណីខ្មែរយើងចូលចិត្តមើលយីកេចូលចិត្តមើលរឿងស្ដាប់ យីកេអីចឹងហាស

ក៖ បាទពូបាទ?

ខ៖ នឹងហើយ

ក៖
ចុះពូគិតថាមាននរណាគេម្នាក់នៅក្នុងក្រុមគ្រួសាររបស់ពូនឹងចេះលេងឧបករណ៍ភ្លេងទេពូ?

ខ៖ អត់មានទេអត់ចេះសោះនឹង

ក៖ បងប្អូនអីក៏អត់ចេះដែរ?

ខ៖ បងប្អូនអីក៏អត់ចេះឧបករណ៍ភ្លេងទេ

កៈ ចុះផ្ទះរបស់ពូនឹងមានលក្ខណៈបែបណាតាំងពីក្មេងរហូតមកដល់ពេលនេះហាសពូ?

ខៈ មុនដំបូងនឹងខ្ទមតូចទេ
រួចពីយើងធ្វើខ្ទមតូចទៅយើងក៏បានរកស៊ីកាក់កបទៅយើងអាចធ្វើផ្ទះសមរម្យ
ដែរយើងអាចរស់នៅបាន

កៈ បាទពូបាទ?

ខៈ នឹងហើយចឹង

កៈ ចុះផ្ទះរបស់ពូនឹងដូចជាពូជួលគេធ្វើរឺមួយក៏ពូធ្វើខ្លួនឯងដែរ?

ខៈ ជួលគេទាំងអស់នឹងយើងចាំតែនៅទៅ

កៈ អូ៎!បាទពូបាទ?

ខៈ យើងជួលគេនឹង

កៈ ចុះពូគិតថាគេធ្វើឧបករណ៍អីគេខ្លះសំរាប់ធ្វើផ្ទះមួយនឹងហាសពូ?

ខៈ ឧបករណ៍អីចាក់ជើងស៊ីម៉ង់នឹងទៅ គ្រឿងឈើនឹងទៅប្រកក្បឿងនឹងមក រនាបឬស្សី
ឆ្កុតមែនឧបករណ៍គេយកអានឹងកាំបិត ពូថៅ ពន្លាកអី អើយនឹងកាំបិត ពូថៅ
ពន្លាកនឹងហាសច្រឡំស្មាន តែគេធ្វើផ្ទះនឹងហោស ធ្វើផ្ទះមានកាំបិត ពូថៅ
ពន្លាកនឹងហើយឧបករណ៍ធ្វើផ្ទះនឹងហើយ បើអោយធ្វើនេះយើងចាក់ជើងធម្មតានឹងហើយ
ឧបករណ៍ធ្វើផ្ទះនឹងមានស៊ីម៉ង់អីណា

កៈ អត់ទេអ៊ីត្រូវទាំងអស់នឹង?

ខៈ ធ្វើផ្ទះអ៊ីធ្វើផ្ទះនឹងហើយ

កៈ គេយកទាំងអស់នឹង?

ខៈ នឹងហើយ

កៈ ចុះចឹងជំនាញអីដែរពូគិតថាពូចេះស្ទាត់ជំនាញហាស?

ខៈ ជំនាញស្ទាត់ជាងគេនឹងគឺឡើងត្នោតនឹងតែម្តងនឹង

កៈ ឡើងត្នោតនឹងហោសពូ?

ខៈ នឹងហើយនិយាយអោយចំៗសំនួរហើយយើងឆ្លើយចំនឹងហើយ

កៈ បាទពូបាទ?

ខៈ នឹងហើយគេឆ្លើយចំ

កៈ ចុះពូគិតថាឪពុកម្តាយរបស់ពូនឹងធ្លាប់បង្រៀនពីជំនាញអីទៅពូដែរទេដូចជាវេញវល្លិ៍ធ្វើផ្តៅ កូរស្កត្នោតរឺក៏?

ខៈ ចុះកាលពីជំនាន់ណុងឪពុកគាត់ឡើងត្នោតដែរ
ឪពុកនឹងឡើងត្នោតនឹងក៏ខ្ញុំមិនដឹងថាឪពុកឡើង
ត្នោតដែរពីព្រោះខ្ញុំនៅតូចណាស់ខ្ញុំមិនដឹងទេ

កៈ ប៉ុន្តែពូចេះកូរស្កត្នោតដែរទេពូ?

ខៈ ចេះកូររឹកៗៗចុះចេះឡើងត្នោតហើយមិនចេះកូរយ៉ាងម៉េច

កៈ បាទពូបាទ?

ខៈ នឹងហើយកូររឹកៗៗនឹងហើយ

កៈ ចុះពូគិតថាការលំបាករបស់ពូនឹងពូឆ្លងកាត់វាដោយរបៀបណាដែរពូ?

ខៈ រឿងពិបាកនឹងវាឆ្អែតហើយនឹងវាចតអស់10កាសែតក៏វាមិនអស់ដែរចឹងហាស
វែកអូសវែកអីចឹងអូថា វាឆ្អែតឆ្អន់វាពិបាកណាស់
កាលណុងនៅផ្សារថ្មីនឹងផ្សារក្រឡុកនឹងហោស

កៈ
ចុះពូគិតថាពេលណាដែរពូគិតថាជាពេលដែរសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់ពូដែរ?

ខៈ ពេលឥឡូវនឹងហោស

កៈ តាំងពីក្មេងមកនឹងពូគិតថាពេលណាដែរពូគិតថាពូសប្បាយជាងគេដែរ?

ខ៖
ពេលទុកនឹងគ្មានរឿងសប្បាយទេឥឡូវនឹងគ្រាន់តែថាយើងដករំលែកទុកគ្រាន់បើបន្តិច
ថាអោយសប្បាយហូនឹងគ្មានទេ

ក៖ ចុះពេលដែរពូការនឹងពូគិតថាពូសប្បាយអត់?

ខ៖ ការសប្បាយតើ សប្បាយចិត្តថាបានប្រពន្ធហើយនឹង

ក៖ ជិតបានប្រពន្ធហោសពូ?

ខ៖ អាអ៊ាវហែងកុំចេះតែនិយាយ

ក៖ ចុះពូគិតថា?

ខ៖ គិចវាចាក់អោយម៉ែវាស្តាប់

ក៖
ចុះពូគិតថាតាំងបីក្មេងហាសពូធ្លាប់មានក្តីស្រម៉ៃថាពេលដែរពូធំឡើងនឹងពូចង់ធ្វើអីទេពូ?

ខ៖
អ៊ូ!ដូចជាមិនចង់ធ្វើអីទេបើម៉ែឪនឹងវាទាល់ហើយក្រខ្សត់គាត់មេម៉ាយអោយយើងរកស៊ីគាត់
គ្មាន
លទ្ធភាពណាអោយយើងរកស៊ីដូចថាជំនួញជួញដាក់ថាម៉េចអត់ទេដឹងតែយើងធំតិចទៅដឹ
ងថាម៉ែអញ់នឹង ក្រណាស់

ក៖ បាទពូ?

ខ៖ គាត់នៅតែម្នាក់ឯងមិនមានប្តីចឹងមានតែមុខរបរដូចថាឡើងត្នោតចឹងទៅ

ក៖
ចុះពូគិតថាបើសិនជាចង់អោយពូផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗពូចង់ផ្តែផ្តាំអីទៅពួកគាត់
ដែរពូ?

ខ៖ ចង់ផ្តែផ្តាំអីគ្រាន់តែចង់ថាចេះថាជំនាន់ក្រោយកូនយើងអីចឹងហាស
ផ្តែផ្តាំគាត់ថាចេះថាកូនអើយប៉ា ឡើងត្នោតឆ្អែតហើយនឹង
កូនក្រោយៗនឹងកុំអោយឡើងត្នោតនឹងវាពិបាកណាស់ឡើងត្នោតនឹង

ចុះឡើងចុងឈើវាមិនដែរស្រួលទេ នឹងហើយចុងឈើវាមិនដែរស្រួលទេ ថាកូនឯងកុំឡើងត្នោត

កៈ បាទពូ?

ខៈ នឹងហើយកុំអោយឡើងត្នោត រកស៊ីអីផ្សេងធ្វើម៉េចអោយជើងជាប់ដី

កៈ បាទពូបាទនឹង?

ខៈ អាជើងឡើងត្នោតនឹងពាក្យចាស់គេថាមួយចំហ៊ានស្លាប់មួយចំហ៊ានរស់ហាស

កៈ បាទត្រូវពូ?

ខៈ តោងមិនជាប់នឹងវាធ្លាក់ស្លាប់ហើយចុងត្នោតនោះមិនរស់ទេ

កៈ
បាទពូចុះបើសិនជាចង់អើយពួកគាត់ជៀសវៀងវិញតើពូចង់អោយពួកគាត់ជៀសវៀងអីគេដែរពូ?

ខៈ ជៀសវៀងអាការឡើងត្នោតនឹង

កៈ ចុះបើសិនជាធ្វើអំពើអីមិនល្អអីចឹងទៅ?

ខៈ ហ៎ា!មិនអោយធ្វើទេអំពើអត់ល្អដឹងតែធ្វើអំពើល្អតែម្តងនឹង

កៈ ចឹងបានថាចង់អោយពួកគាត់ជៀសវៀងអីគេ?

ខៈ ជៀសវៀងជាពិសេសនឹងថាកុំអោយតែទៅឆក់ ប្លន់គេ នឹងហើយជក់គ្រឿងញៀន

កៈ បាទពូបាទ?

ខៈ ជៀសផុតអារឿងគ្រឿងញៀននឹងតែម្តងនឹងកុំអោយចូលគុកនឹងវាមិនស្រួលទេ

កៈ បាទពូបាទ?

ខៈ នឹងហើយៗ

កៈ មានអីចង់ផ្តែផ្តាំអីផ្សេងទៀតទេពូ?

ខ៖ អត់មានទេមានតែប៉ុណ្ណឹងទេចង់ផ្តាំកុំអោយកូននឹងជក់គ្រឿងញៀននឹង លេងបៀរ លេងអាប៉ោងនឹង

កុំអោយប្លន់គេ រឺក៏លួចគេបើថាធ្វើជាសំណាង់ធ្វសំណាង់ទៅ ធ្វើអីក៏ដោយធ្វើអោយសុចរិតកុំអោយចេះ ឆក់ប្លន់គេចឹងហាស

ក៖ បាទពូនឹងហើយ?

ខ៖ នឹងហើយកុំអោយទាក់ទងខាងនឹង

ក៖ ចឹងជាចុកក្រោយខ្ញុំអរគុណពីដែរបានអោយខ្ញុំបានសំភាសន៍ពីប្រវត្តិរបស់ពូ

ខ៖ នឹងហើយ

ក៖ ហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដើម្បីតំកល់ទុកអោយពូចឹង ហាសពូបាទ៕៕៕